## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១២

# ជប៉ុនផ្តល់ ១២១,៨២៨ ដុល្លារអាមេរិក សម្រាប់គម្រោងសហគមន៍ថែទាំសុខភាពមូលដ្ឋានសម្រាប់មាតា និងទារក

ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន



រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន **១២១,៨២៨ ដុល្លារអាមេរិក** ដល់អង្គការ**មូលនិធិជប៉ុន -ភី . អេចស៍** ដើម្បីគាំទ្រគម្រោងសហគមន៍ថែទាំសុខភាពមូលដ្ឋានសម្រាប់មាតានិងទារកនៅក្នុងខេត្តកំពង់ធំ (ដំណាក់កាលទី២)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះដោយ ឯកឧត្តមម៉ាសាហ្វូមី គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោកស្រីKUME Yumikoតំណាងប្រចាំប្រទេសអង្គការ**មូលនិធិជប៉ុន -ភី.អេចស៍** នៅស្ថានទូតជប៉ុន។

ដោយបានចំណាយធនធានសម្រាប់ការធ្វើសកម្មភាពក្នុងស្រុកប្រតិបត្តិបារាយណ៍-សន្ទុក ខេត្ត



កំពង់ធំដែលជាតំបន់គោលដៅក្នុងដំណាក់កាលទីមួយ អង្គការ**មូលនិធិជប៉ុន - ភី . អេចស៍**នឹងបន្តធ្វើការបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តសុខភាពតាមសហគមន៍ដែលជាធនធានដ៏សំខាន់ក្នុងការផ្តល់សេវាថែទាំសុខភាពមាតា និងទារកក្នុងតំបន់។ អង្គការ**មូលនិធិជប៉ុន -ភី . អេចស៍**ក៏នឹងរៀបចំយុទ្ធនាការសំអាត ជួយសាងសង់បង្គន់អនាម័យនៅតាមផ្ទះ ព្រមទាំងគាំទ្រក្នុងការបង្កើតទំនាក់ទំនងល្អរវាងអ្នកស្ម័គ្រចិត្តសុខភាពតាមសហគមន៍ និងបុគ្គលិកក្នុងមណ្ឌលសុខភាព។ នៅពេលគម្រោងតំណាក់កាលទី២ត្រូវបានបញ្ចប់ យើងរំពឹងថាប្រជាពលរដ្ឋប្រមាណ៤៧,០០០នាក់អាចអនុវត្តសេវាថែទាំសុខភាពមាតានិងទារកព្រមទាំងការថែទាំអនាម័យជាប្រចាំដោយប្រើប្រាស់ធនធាននៅក្នុងតំបន់។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ១៥.៥លានដុល្លាអាមេរិក ដល់គម្រោង ៦៥ របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និងសកម្មភាពបោសសំអាតមីន។ គម្រោងរបស់អង្គការ**មូលនិធិជប៉ុន-ភី. អេចស៍** នេះគឺជាគម្រោងទី១តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១២របស់ជប៉ុន (មេសា ២០១២ ដល់ មិនា ២០១៣)




ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp